ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ
លេខ:..................អសជ/.....

# របាយការណ៍សវនកម្ម
# លើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រង
# ចំណូលមិនមែនសារពើពន្ធនៅខេត្តកំពង់ឆ្នាំង

## ការិយបរិច្ឆេទ២០២៣

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA
Tel:(855-23) 885 900, (855-12) 737 622 Fax: (855-23) 885 900
E-mail: naakh@naa.gov.kh website: www.naa.gov.kh

## របាយការណ៍សង្ខេប

រាជរដ្ឋាភិបាលបានដាក់ចេញនូវ "យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥" ដែលជាការកែទម្រង់រយៈពេលវែង និងគ្រប់ជ្រុងជ្រោយក្នុងគោលដៅពង្រឹង និងពង្រីកការអនុវត្ត "ថវិកាកម្មវិធី" ជាបណ្តើរៗ ដើម្បីធានាឱ្យបានការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគោលបំណង គោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតម្រឹមជាមួយនឹងគោលបំណង/អាទិភាព គោលនយោបាយជាតិ។ ក្នុងគោលដៅនេះ ការធ្វើសមាហរណកម្មផែនការនីយកម្មមានភាពចាំបាច់ ដើម្បីឱ្យផែនការយុទ្ធសាស្ត្ររដ្ឋបាលថ្នាក់ក្រោមជាតិមានការផ្សារភ្ជាប់ទំនាក់ទំនងគ្នា បំពេញឱ្យគ្នា និងប្រទាក់ក្រឡាគ្នាទៅវិញទៅមក និងតម្រឹមទៅនឹងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ (មន្ទីរជំនាញរាជធានី ខេត្ត)។ ការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកាគឺធ្វើការកែលម្អ និងផ្លាស់ប្តូរជាជំហានៗ នៃវដ្តថវិកានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ពិសេសការកំណត់ឱ្យបានត្រឹមត្រូវច្បាស់លាស់អំពីសិទ្ធិអំណាច និងការទទួលខុសត្រូវតាមដំណាក់កាលនៃវដ្តថវិកា ដែលរួមទាំងការធ្វើឱ្យស្ថាប័ននីយកម្មជាបណ្តើរៗនៃរបាយការណ៍ហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញដើម្បីផ្តល់ជាគោលការណ៍ណែនាំថ្មីៗសម្រាប់ជាមូលដ្ឋាន និងជាក្របខ័ណ្ឌសម្រាប់ការរៀបចំកញ្ចប់ថវិកាឆ្នាំ២០២៣។

រដ្ឋបាលខេត្តកំពង់ឆ្នាំង បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំដោយផ្អែកតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដើម្បីកំណត់នូវក្របខ័ណ្ឌ និងវិធានការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល អាទិភាពចំណាយ និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា។ រដ្ឋបាលខេត្តបានរៀបចំរចនាសម្ព័ន្ធថវិកាកម្មវិធី និងគម្រោងចំណូល ចំណាយថវិកាឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ ដើម្បីឱ្យការរៀបចំគម្រោងថវិកានេះអាចប្រព្រឹត្តទៅបានរលូន និងគ្រប់ជ្រុងជ្រោយ ជាពិសេសឈានទៅសម្រេចបានគោលដៅនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ រដ្ឋបាលខេត្តបានរៀបចំផែនការដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ការរៀបចំគម្រោងថវិកាប្រចាំឆ្នាំនេះបានគ្របដណ្តប់គ្រប់ប្រភពចំណូលទាំងអស់ និងគ្រប់មុខសញ្ញាចំណាយទាំងអស់។ ការរៀបចំថវិកាបានផ្អែកលើលទ្ធផលនៃការអនុវត្តឆ្នាំមុន បែបបទ និងនីតិវិធីដែលបានកំណត់ និងគោលការណ៍ចំណាយចាំបាច់នានា ជាពិសេសត្រូវធានាឱ្យមានតុល្យភាពពិតប្រាកដរវាងចំណូល និងចំណាយថវិកា ដើម្បីធានាដល់គណនេយ្យភាពក្នុងការប្រើប្រាស់ធនធានសាធារណៈឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

រដ្ឋបាលរាជធានី ខេត្ត បានរៀបចំគម្រោងចំណូល និងខិតខំពង្រឹងជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពផ្អែកលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន[១]។

---

[១] សារាចរណែនាំលេខ០០៦សហវ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ គ្រង់ចំណុច៣.១

តាមគម្រោងផែនការចំណូល ចំណាយថវិការបស់រដ្ឋបាលខេត្តចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ ការគ្រោងចំណូលមិនមែនសារពើពន្ធសម្រាប់ឆ្នាំ២០២៣ មានទឹកប្រាក់សរុប ៦ ៣៤១ ០០០ ០០០ រៀល ក្នុងនោះ ចំណូលពីឧបត្ថម្ភ និងអំណោយមានចំនួន ៣ ៣៣០ ០០០ ០០០ រៀល ហើយចំណូលមិនមែនសារពើពន្ធដែលត្រូវប្រមូលមានចំនួន ៣ ០១១ ០០០ ០០០រៀល ។ ក្រោយពីការប្រជុំឆ្លងកញ្ចប់ថវិកាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចមក រដ្ឋសភាបានអនុម័តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ក្នុងនោះ ចំណូលមិនមែនសារពើពន្ធសម្រាប់រដ្ឋបាលខេត្តកំពង់ឆ្នាំងមានទឹកប្រាក់សរុបចំនួន ១១ ៣៤១ ០០០ ០០០ រៀល ដែលរួមមាន ចំណូលពីការឧបត្ថម្ភ និងអំណោយមានទឹកប្រាក់សរុប ៨ ៣៣០ ០០០ ០០០ រៀល ដូច្នេះ ចំណូលមិនមែនសារពើពន្ធដែលរដ្ឋបាលខេត្តត្រូវប្រមូលមានចំនួន ៣ ០១១ ០០០ ០០០ រៀល។

គោលបំណងនៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅខេត្តកំពង់ឆ្នាំងសម្រាប់ការិយបរិច្ឆេទ២០២៣ ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ ដោយផ្តោតសំខាន់លើៈ

- ការរៀបចំគម្រោងផែនការប្រមូលចំណូលមិនមែនសារពើពន្ធ
- ការអនុវត្តប្រមូលចំណូលមិនមែនសារពើពន្ធ
- ការតាមដានលើបំណុលមិនមែនសារពើពន្ធ

អាជ្ញាធរសវនកម្មជាតិ បានចុះធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលខេត្តកំពង់ឆ្នាំងសម្រាប់ការិយបរិច្ឆេទ២០២៣ ដោយសូមបង្ហាញជូននូវលទ្ធផលសវនកម្ម ដូចខាងក្រោមៈ

### ១ . ការគ្រោងផែនការចំណូលមិនមែនសារពើពន្ធមិនទាន់អស់លទ្ធភាព

តាមច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ បានតម្រូវឱ្យរដ្ឋបាលខេត្តកំពង់ឆ្នាំងត្រូវប្រមូលចំណូលមិនសារពើពន្ធមានចំនួន៣ ០១១ ០០០ ០០០ រៀល។ ទន្ទឹមនឹងនេះ តាមការពិនិត្យសំណុំឯកសារចំណូលមិនមែនសារពើពន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្ត និងមន្ទីរ អង្គភាពជំនាញ មិនទាន់បានគ្រោងមុខសញ្ញាចំណូលមិនមែនសារពើពន្ធមួយចំនួននៅក្នុងកញ្ចប់ថវិកាឆ្នាំ២០២៣ នៅឡើយ ក្នុងនោះមាន ៖

១. ការមិនបានបង់ចំណូលពីសួយសារផលិតផលរ៉ែរបស់ក្រុមហ៊ុន ស៊ូមីតូម៉ូ មីតស៊ុយ ខលស្ត្រាក់សិន ចំនួន១ អាជ្ញាបណ្ណ មាន១០ទីតាំង មានទឹកប្រាក់សរុបចំនួន៥៩៣ ១០៤ ដុល្លារអាមេរិក។

២. ការមិនទាន់បានផ្ទេរចំណូលពីសម្បទាននេសាទ (រដ្ឋបាលជលផល) មានទឹកប្រាក់សរុបចំនួន៧៨ ៨០០ ០០០ រៀល។

៣. ចំណូលពីសេវាហិរញ្ញប្បទាន១% និងសេវាផ្សេងៗ ៧៥% ដែលមានទឹកប្រាក់សរុបចំនួន ៣៦ ២៨៩ ៨០០ រៀល។

## ២. កង្វះខាតក្នុងការប្រមូលចំណូលពីអាជ្ញាប័ណ្ណសួយសាររ៉ែ

តាមការពិនិត្យរបាយការណ៍ចំណូលធនធានរ៉ែឆ្នាំ២០២៣ របស់មន្ទីររ៉ែ និងថាមពលខេត្តកំពង់ឆ្នាំង បានបង្ហាញថា មន្ទីរបានខិតខំកៀគរប្រមូលចំណូលសួយសារលើផលិតផលរ៉ែសរុបចំនួន៧ អាជ្ញាបណ្ណ ដែលមានទឹកប្រាក់សរុបចំនួន ១ ៥៣៨ ៥៨៣ ០៣៤ រៀល ក្នុងនោះ បានបង់ចូលថវិកាជាតិ ៥០% ដែលមានទឹកប្រាក់សរុបចំនួន ៦៨០ ៦៤៦ ២៧២ រៀល និងបានបង់ចូលថវិកាថ្នាក់ក្រោមជាតិចំនួន៥០% ដែលមានទឹកប្រាក់សរុបចំនួន ៨៥៧ ៩៣៦ ៧៧៦ រៀល។ ទន្ទឹមនឹងនេះ តាមការពិនិត្យឯកសារនៅមន្ទីររ៉ែនិងថាមពលបានបង្ហាញថា មានក្រុមហ៊ុន សហគ្រាសចំនួន១៣ ដែលមានអាជ្ញាបណ្ណសរុបចំនួន២២ ក្នុងនោះ មានក្រុមហ៊ុនមួយដែលទទួលបានអាជ្ញាបណ្ណដីក្រហម និងដីល្បាយខ្សាច់ចំនួន ១០(អាជ្ញាបណ្ណ) ទីតាំង នៅពុំទាន់បានបង់ចំណូល ពីសួយសារលើផលិតផលរ៉ែនៅឡើយ។

## ៣. កង្វះខាតវិធានការក្នុងការតឹងទារបំណុលមិនមែនសារពើពន្ធ

តាមការពិនិត្យឯកសារការប្រមូលចំណូលពីភាស៊ី និងចំណូលពីសេវាផ្សេងៗ និងចំណូលពីការពិន័យរបស់មន្ទីរ អង្គភាពជំនាញសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តនៅមិនទាន់មានវិធានការតឹងទារបំណុលសារពើពន្ធលើម្ចាស់អាជីវកម្ម និងសហគ្រាសមួយចំនួនដែលនៅជំពាក់បំណុលពីភាស៊ីគ្រប់ប្រភេទទូទាំងខេត្តដែលមានទឹកប្រាក់សរុបចំនួន១៣១ ៧៧១ ៥០០ រៀល និងបំណុលកុំរ៉ៃពីសម្បទានរ៉ែ ដែលបានបន្សល់ទុកយូរឆ្នាំមកហើយមានទឹកប្រាក់សរុបចំនួន ១៥ ០០០ ដុល្លារអាមេរិក និងចំនួន១២ ៥៧៧ ៧០០ រៀល។

ឆ្លងតាមលទ្ធផលនៃការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលខេត្តកំពង់ឆ្នាំងសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិអាចសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍មួយ ដូចខាងក្រោម៖

- **សេចក្តីសន្និដ្ឋាន**

រដ្ឋបាលខេត្តកំពង់ឆ្នាំងបានខិតខំអនុវត្តប្រមូលចំណូលមិនមែនសារពើពន្ធសម្រាប់ការិយបរិច្ឆេទ ២០២៣ បានចំនួន២ ៧២៣ ១៤៨ ៩៨១ រៀលស្មើនឹង ៩០,៤៥% បើប្រៀបធៀបនឹងគម្រោងផែនការដែលមានក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលមានទឹកប្រាក់៣ ០១១ ០០០ ០០០ រៀល។ ទន្ទឹមនឹងនេះផងដែរ តាមរយៈបញ្ហាគួរឱ្យកត់សម្គាល់ក្នុងការធ្វើសវនកម្មខាងលើ រដ្ឋបាលខេត្តនៅមិនទាន់បានគ្រប់គ្រងមុខសញ្ញាចំណូលមិនមែនសារពើពន្ធឱ្យអស់លទ្ធភាពនៅឡើយ។ ព្រមជាមួយគ្នានេះ ការប្រមូលចំណូលមិនមែនសារពើពន្ធរបស់រដ្ឋបាលខេត្តក៏នៅមិនទាន់អស់លទ្ធភាពផងដែរ ដោយមន្ទីររ៉ែ និងថាមពលនៅមិនទាន់បានប្រមូលចំណូលសួយសារផលិតផលរ៉ែលើអាជ្ញាបណ្ណមួយចំនួន ថែមទាំងនៅមានបំណុលមិនមែនសារពើពន្ធ ដែលរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធនៅមិនទាន់មានវិធានការតឹងទារបំណុល ដែលជាហេតុនាំរដ្ឋបាលខេត្ត មិនអាចប្រមូលចំណូលសម្រេចបានតាមផែនការ និងមិនអាចធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈក្នុងខេត្តឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

• **អនុសាសន៍**

តាមរយៈការចុះធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលខេត្តកំពង់ឆ្នាំងសម្រាប់ការិយបរិច្ឆេទ២០២៣ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលខេត្តកំពង់ឆ្នាំង បានអនុវត្តការប្រមូលចំណូលនៅមិនទាន់អស់លទ្ធភាព ដោយមានបន្សល់ទុកនៅចំណូលផ្សេងៗទៀតដែលមិនទាន់បានដាក់បញ្ចូលក្នុងគម្រោងផែនការ និងមុខសញ្ញាចំណូលខ្លះមន្ទីរជំនាញមិនអាចប្រមូលបាន ព្រមទាំងបន្សល់ទុកនូវបំណុលផងដែរ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តកំពង់ឆ្នាំងគួរតែពិនិត្យឡើងវិញលើការគ្រោងចំណូលនៅឆ្នាំបន្តបន្ទាប់ទៀត សំខាន់ត្រូវស្វែងរកប្រភពចំណូលដែលនៅសល់មិនទាន់បានប្រមូល ដើម្បីកំណត់នូវក្របខ័ណ្ឌ និងវិធានការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល និងគោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការអនុវត្តថវិកា។

• **មតិរបស់រដ្ឋបាលខេត្តកំពង់ឆ្នាំង**

រដ្ឋបាលខេត្តកំពង់ឆ្នាំង សូមទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ ហើយរដ្ឋបាលខេត្តកំពង់ឆ្នាំង នឹងខិតខំពង្រឹង និងកែលម្អនូវចំណុចខ្វះខាតទាំងឡាយនៅឆ្នាំបន្តបន្ទាប់ឱ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។